# សិទ្ធិបោះឆ្នោត និង ចលនាពលរដ្ឋ : ធ្វើឲ្យសម្លេងអ្នកបានឮ



**ការ**បោះឆ្នោតក្នុងពេលជ្រើសរើស ជាផ្លូវមួយដែលមានអំណាចខ្លាំង សំរាប់ធ្វើឲ្យសម្លេងអ្នកបានឮ។ ការបោះឆ្នោតមិនមែនភ្ជាប់ជានិច្ច ជាសិទ្ធិមួយ របស់មនុស្សម្នាក់ៗនៅក្នុងស្រុក អាមេរិក U.S. នោះទេ។ ដោយហេតុនេះ ជាពិសេសនិងសំខាន់ណាស់ សំរាប់ប្រជាពលរដ្ឋដែលមានសញ្ជាតិគ្រប់រូប ទៅប្រើសិទ្ធិរបស់ខ្លួន ក្នុងការបោះឆ្នោតនៅគ្រប់ការជ្រើសរើសទាំងអស់។ ការទាំងនេះអត់មានអស់លុយទេ ហើយជាការទទួលរាប់រង របស់ប្រជាពលរដ្ឋល្អផង។

ក៏បន្តែ អ្នកដែលគ្មានសញ្ជាតិក៏អាចចូលរួម ក្នុងការបោះឆ្នោតជ្រើសរើសបាន - ដោយសារការជួយអ្នកដទៃទៀត ឲ្យចុះឈ្មោះសំរាប់បោះឆ្នោត រៀបចំការផ្តុំគ្នា នឹងធ្វើការនៅតាមវិហារសាសនាគេ នឹងតាមសាលារៀនកូនរបស់គេ ដើម្បីរៀនអំពីចំណុចរឿង នឹងការពិភាក្សារឿងនោះជាមួយសមាជិកគ្រួសារគេ ឬអ្នកជិតខាងដែលអាចមានសិទ្ធិបោះឆ្នោតបាន ហើយគឺថាគេត្រូវចូលខ្លួនជួយឲ្យបានយ៉ាងច្រើនបំផុតដែលគេអាចធ្វើទៅបាននៅពេលបោះឆ្នោតនោះ។

## តើអ្នកណា អាចបោះឆ្នោតបាន?

ដើម្បីនឹងបោះឆ្នោតបាន អ្នកនោះត្រូវ:

- មានសញ្ជាតិអាមេរិកកាំង
- យ៉ាងហោចណាស់ក៏មានអាយុ ១៨ឆ្នាំឡើងលើ
- អ្នកមិននៅក្នុងគុក ឬជាអ្នកទោសដែលមានគេឃ្លាំមើល
- ត្រូវតែចុះឈ្មោះបោះឆ្នោត យ៉ាងតិចណាស់ ១៥ថ្ងៃមុន
- អ្នកដែលទើបមានសញ្ជាតិថ្មីៗ ត្រូវទៅចុះឈ្មោះកន្លែង **Office of the Registrar Voter** បាន៧ថ្ងៃនៅមុនថ្ងៃបោះ ឆ្នោតណាមួយ។

## ថ្វីបើអ្នកមិនអាចបោះឆ្នោតបាន អ្នកក៏អាចចូលរួមក្នុងសកម្មភាពបោះឆ្នោតជាច្រើន។ គឺជា **សិទ្ធិ** របស់អ្នក !

### តើខ្ញុំត្រូវចុះឈ្មោះបោះឆ្នោតយ៉ាងដូចម្តេចដែរ?

អ្នកត្រូវចុះឈ្មោះបោះឆ្នោត ដោយបំពេញនូវក្រដាសចុះឈ្មោះ ដោយផ្ទាល់នឹងបុគ្គល ឬដោយសំក្រដាសបំពេញនោះ តាមការផ្ញើតាមប៉ុស្តិ៍ ឬតាមរយៈខ្សែ អិនទើណិត។

អ្នកអាចសុំក្រដាស់ចុះឈ្មោះ ពីកន្លែងអ្នកនៅ :

- កន្លែងប៉ុស្តិ៍ដែលនៅទីកន្លែងអ្នក
- ក្រសួងសបាគម
- បណ្ណាល័យ
- កន្លែងបំរើសង្គម
- កន្លែង WIC
- កន្លែង DMV
- នៅកន្លែង County Registrar of Voter

  1555 Berger Dr., Bldg. 2 in San Jose.
  ឬក៏អ្នកអាចទៅជួបបុគ្គលដោយផ្ទាល់ ដើម្បីយកក្រដាសចុះឈ្មោះ ឬក៏ទូរស័ព្ទទៅសុំ ដោយប្រើលេខ
  (408) 299-VOTE (8683.)

អ្នកក៏អាចរកបាន នូវក្រដាសចុះឈ្មោះនេះ ពីកន្លែង អិនទើណិតនៅអស័យដ្ឋាន ដូចតទៅ www.sccvote.org ឬក៏នៅកន្លែង California Secretary of State អស័យដ្ឋានដូចនេះ www.ss.ca.gov. ។ តែទោះជាយ៉ាងណាក៏ដោយ អ្នកត្រូវតែកុំភ្លេចចុះហត្ថលេខា នឹងផ្ញើក្រដាសចុះឈ្មោះបោះឆ្នោតនោះ ទៅឲ្យការិយាល័យបោះឆ្នោត ក្នុងកន្លែងអ្នករស់នៅ។

*សូមចាំថា:*

- ក្រដាស់ចុះឈ្មោះបោះឆ្នោតនោះ មានជាភាសាដ៏ច្រើន។
- បើអ្នកចង់ អាចរកអ្នកណាមួយ ជួយបំពេញក្រដាសចុះឈ្មោះបោះឆ្នោតនោះក៏បានដែរ។

- ក្រដាសចុះឈ្មោះនោះ អាចផ្ញើទៅតាមប៉ុស្តិ៍ មិនចាំបាច់បិតតែមទេ។

## តើមានហេតុអ្វីក្រោយដែលខ្ញុំចុះឈ្មោះបោះឆ្នោតនោះ?

បីអាទិត្យមុនការបោះថ្ងៃឆ្នោត អ្នកនឹងបានទទួលពត៌មានពីកន្លែង Office of the Registrar of Voters ឈ្មោះថា "Sample Ballot," គឺជាសៀវភៅតូចមួយពីការសង្ខេបពីចំណុចរឿងនិមួយៗ នឹងការសសេរប្រាប់ពី អ្នកឈរឈ្មោះ ដែលចង់ធ្វើជាដំណាងអ្នក នៅការិយាល័យនោះ។ ឧទាហរណ៍នៃសន្លឹកឆ្នោត នឹងប្រាប់អ្នកច្បាស់នូវកន្លែងទៅបោះឆ្នោត។

---

## ការបោះឆ្នោតជាការសំខាន់ណាស់ សំរាប់ប្រើសិទ្ធិរបស់ខ្លួន ឲ្យគេបានដឹងឮ

---

## តើខ្ញុំអាចរកពត៌មានសំរាប់បោះឆ្នោតឯណាដើម្បីដឹងពីចំណុចរឿង និង អ្នកឈរឈ្មោះសំរាប់បោះឆ្នោតនោះ?

អ្នកអាចខ្លាយជាមនុស្ស ដែលមានការចេះដឹងអំពីការបោះឆ្នោត ដោយប្រើសម្ភារៈច្រើនយ៉ាងដែលមាន នៅក្នុងសហគមអ្នក។ សម្ភារៈអ្វីដែលអ្នកប្រើក៏ដោយ អ្នកត្រូវតែដឹងនឹងយល់ច្បាស់ឲ្យបានពិតប្រាកដ នូវចំណុចរឿង និងអ្នកឈរឈ្មោះនោះ។

អ្នកអាចរៀនបន្ថែមពី ចំណុចរឿង និងអ្នកឈរឈ្មោះ ដោយប្រើការផ្តល់ដូចតទៅ :

- និយាយជាមួយគ្រួសារ នឹងអ្នកជិតខាង
- **The *Easy Reading Voting Guide*-** ជាសៀវភៅសរសេរដោយ League of Women Voters ដែលស្រួលមើលនឹងស្រួលយល់។ អ្នកអាចរកបាននៅបណ្ណាល័យសាធារណៈ នៅក្នុងក្រុមរៀបចំសហគម និង កន្លែង Registrar of Voters offices.
- ស្តាប់តាមវិទ្យុ
- តាមសន្ទរៈកថា នឹងការចេញខ្លួនជាសាធារណៈ
- អក្សរសាសន៍ពីការផ្សប់ផ្សាយ - ក្រដាសផ្សាយ សំបុត្រ និងសៀវភៅតូចៗដែលទទួលបានតាមប៉ុស្តិ៍
- ការជជែកតាមទូរស័ព្ទ
- សៀវភៅចេញរាល់អាទិត្យ ឬរាល់ខែ
- មើលសារពត៌មាន នឹងមើលដំណឹងក្នុងទូរទស្សន៍
- ទាក់ទង នឹងកន្លែងធ្វើការឬអ្នកឈរឈ្មោះ ដោយផ្ទាល់ ហើយសួរថាតើគេមានជំហ៊រយ៉ាងណា?
- ទាក់ទង នឹងករិយាល័យធំ នៃផ្នែកនយោបាយ ដែលអ្នកមានការយល់ពេញចិត្ត នឹងសួរគេឲ្យផ្ញើមកអ្នកនូវពត៌មានផ្នែកណាដែលអ្នកចង់ដឹង។
- ការជួយឲ្យយោបល់ ពីក្រុមសមាគម ដែលអ្នកជាសមាជិកមួយរូប ហើយដែលជាទូទៅ អ្នកមានគំនិតឬយោបល់ស្របតាមសមាគមនោះ។
- *Project Vote Smart* ក៏ជាកន្លែងល្អមួយដែលសំរាប់ផ្តល់ប្រដាប់ប្រដារ សំរាប់រៀនអំពីចំណុចរឿង នឹង អ្នកឈរឈ្មោះបោះឆ្នោតនោះ។ នេះជាការរៀបរយមួយ ដែលគ្មានកាន់ជើងប័ក្ខពួកខាងណាមួយ ហើយធ្វើការវិភាគ នូវពត៌មាន ក្នុងស្រុកទាំងអស់ មិនថាអំពីអ្នកធ្វើការឬអ្នកឈរឈ្មោះឡើយ ឲ្យនូវពត៌មានដូចជាសំណុំរឿង នឹងកំណត់កត់ត្រាទុកផ្សេងៗថែមទៀត។ សូមទាក់ទងទូរស័ព្ទតាមលេខនេះ 1-888-VOTESMART (1-888-868-3762) ឬក៏តាមខ្សែ អិនទើណិត www.vote-smart.org.

## ខ្ញុំចង់បោះឆ្នោត ដោយផ្ញើតាមប្រៃសណីយ តើខ្ញុំត្រូវធ្វើដូចម្តេច?

ការបោះឆ្នោត ដោយផ្ញើតាមប្រៃសណីយ ឬហៅថា "Absentee Ballot" គឺជារបៀបបោះឆ្នោតមួយ ដែលប្រជាជន មានសិទ្ធិប្រើបាន ដោយមិនចាំបាច់មានការបង្ហាញ បញ្ជាក់ហេតុផលអ្វីទេ។ មនុស្សច្រើន ចូលចិត្ត "Absentee Ballot" ពីព្រោះគេ អាចបោះឆ្នោតដោយស្ងាត់ស្ងាមនៅក្នុងផ្ទះខ្លួន នឹងគេអាចបោះជាមួយគ្រួសារ នឹងក្រុមគេដែលមានមនុស្សច្រើន។

## តើពេលណាទៅទើប ខ្ញុំអាចសុំ "**Absentee Ballot**" បាន ?

អ្នកអាចសុំ "absentee ballot" បាននៅកំឡុងពេល ២៩ថ្ងៃមុនពេលបោះឆ្នោត ដោយសរសេរសំបុត្រទៅកន្លែងគ្រប់គ្រងការចុះឈ្មោះបោះឆ្នោតឈ្មោះថា Office of the Registrar of Voters ឬក៏ដោយសុំយកសំបុត្រ សំរាប់ California Secretary of State ពីអិនទើណិត (www.ss.ca.gov.) ។ សំបុត្រឆ្នោតនឹងផ្ញើទៅផ្ទះអ្នកដោយផ្ទាល់តែម្តង។

ថ្ងៃទីចុងក្រោយនៃការសុំ "absentee ballot" គឺត្រូវតិចជាង ៧ថ្ងៃមុននៃថ្ងៃបោះឆ្នោតទេ។ អ្នកត្រូវតែសរសេរពត៌មាននៅក្នុងក្រដាសសុំដូចខាងក្រោមនេះ :

- ចំណាងជើង និង ថ្ងៃខែឆ្នាំ នៃការបោះឆ្នោតនោះ។
- កន្លែងលេខអស័យដ្ឋាន ដែលអ្នកត្រូវចុះឈ្មោះ។
- កន្លែងលេខអស័យដ្ឋាន ដែលសំបុត្របោះឆ្នោតត្រូវផ្ញើត្រឡប់មកឲ្យអ្នកវិញ។
- ចុះហត្ថលេខារបស់អ្នក ធ្វើឲ្យដូចហត្ថលេខាដែលអ្នកធ្វើពេលចុះឈ្មោះ។
- លេខទូរស័ព្ទ និង អាយុកំណើត មិនជាការចាំបាច់ទេ។

## តើពេលណាដែលខ្ញុំត្រូវផ្ញើរ **absentee ballot** របស់ខ្ញុំនោះ?

ក្រដាស់បោះឆ្នោតមិនផ្ទាល់ខ្លួន absentee ballot ត្រូវតែបានទទួល មុន ឬក៏នៅចំ ថ្ងៃបោះឆ្នោតនោះ។ អ្នកក៏អាចយកក្រដាស់បោះឆ្នោតមិនផ្ទាល់ខ្លួននោះ absentee ballot ទៅឲ្យមនុស្សដែលធ្វើការនៅកន្លែងបោះឆ្នោត នាថ្ងៃនោះតែម្តង ប៉ុន្តែមិនត្រូវឲ្យយឺតជាងម៉ោង ៨ល្ងាចទេ។

## ខ្ញុំជាអ្នកពិការ ហើយមិនអាចធ្វើដំណើទៅកាន់កន្លែងបោះឆ្នោត ទៅប្រគល់សន្លឹកឆ្នោត **absentee ballot** បាន តើខ្ញុំត្រូវធ្វើដូចម្តេច?

អ្នកអាចបង្គប់ឲ្យបងប្អូនជិតដិត យកសន្លឹកឆ្នោត absentee ballot របស់អ្នក ទៅប្រគល់ឲ្យនៅកន្លែងបោះឆ្នោត ជំនួសខ្លួនអ្នកបាន។ នៅស្រុក សាន់តាក្លារ៉ា អ្នកអាចសុំភាព សន្លឹកឆ្នោត absentee ballot សំរាប់ខ្លួនជាអ្នកពិការឬឈឺធ្ងន់ ទុកសំរាប់បោះឆ្នោតទៅអនាគតខាងមុខ។ សូមទាក់ទងនឹង Registrar of Voters ដើម្បីពត៌មានបន្ថែម។

## ខ្ញុំទើបតែក្លាយជាអ្នកមានសញ្ជាតិ ក្រោយពីថ្ងៃកំណត់ឲ្យចុះឈ្មោះបោះឆ្នោត តើខ្ញុំត្រូវធ្វើយ៉ាងណា?

បើសិនជាខ្ញុំ ទើបតែក្លាយជាអ្នកមាន សញ្ជាតិអាមេរិកកាំង ក្រោយពីថ្ងៃកំណត់ឲ្យចុះឈ្មោះបោះឆ្នោតនោះ អ្នកអាចចុះឈ្មោះទៅឯល់ ៧ថ្ងៃមុនពេលបោះឆ្នោតបាន។ បើសិនជាអ្នកទៅចុះឈ្មោះនៅ Office of the Registrar of Voters អ្នកប្រហែលជាអាចចុះឈ្មោះនៅថ្ងៃបោះឆ្នោតតែម្តង។ អ្នកត្រូវតែយកមកជាមួយនៅ :

- សញ្ញាបត្រិបង្ហាញនូវការចូលសញ្ជាតិរបស់អ្នក
- ក្រដាសឬកាត សំគាល់ខ្លួន

---

**ការបោះឆ្នោតមិនផ្ទាល់ខ្លួន "Absentee Voting"**
**អាចមានភាពស្រួល ហើយអាចបោះជាក្រុមបាន។**
**ធ្វើកំរោងការមួយសំរាប់ "Absentee Voting Day"**
**នៅក្នុងសបាគមអ្នក !!**

---

## ថ្ងៃនេះជាថ្ងៃបោះឆ្នោត តើជាដំបូងខ្ញុំត្រូវធ្វើយ៉ាងដូចម្តេច?

ជាលើកដំបូងអ្នកត្រូវទៅកន្លែងបោះឆ្នោត !!! រកមើល ទីកន្លែងបោះឆ្នោតក្នុងសហាគមអ្នក នៅក្នុងសៀវភៅបោះឆ្នោត sample ballot ដែលអ្នកបានទទួលតាមប៉ុស្តិ។ ទីកន្លែងបោះឆ្នោត មានបើកធ្វើការពីម៉ោង៧ព្រឹក ទៅ ៨ល្ងាច។

ទីកន្លែងបោះឆ្នោត បិតនៅក្នុងផ្នែកខុសៗ ក្នុងសហាគមអ្នក :

- វិហារសាសនា
- សាលារៀន
- ទីកន្លែងសហាគម



ត្រូវការពត៌មានថែមទៀត? សូមទាក់ទងតាមខ្សែទូរស័ព្ទ SIREN's Immigrant Assistance & Information Line សំរាប់កម្មវិធីប្តូរថ្មី នឹងសំនួរជាទូទៅ។ ទូរស័ព្ទទាំងអស់មានបើក ពីថ្ងៃ ចន្ទ-សុក្រ ម៉ោង ១០ព្រឹក-៩ល្ងាច ហើយជាពីរភាសា អង់គ្លេសនឹងភាសាដូចតទៅ :
អេស្ប៉ាញ៉ូល- (408) 286-1698 វៀតណាម- (408) 286-1448 **Farsi**- (408) 286-5680 x108 នឹងចិន- (408) 286-5680 x109

- ទីកន្លែងប្រកបមុខរបរ
- បន្ទប់នៅផ្ទះដាក់ឡាន ហៅថា Garage និងទីកន្លែងផ្សេងទៀត........

**នៅថ្ងៃបោះឆ្នោត...**

1. ដំបូងអ្នកត្រូវទៅជួបជាមួយ នឹងអ្នកស្ម័គ្រចិត្តធ្វើការនៅកន្លែងបោះឆ្នោតនោះ។ គេនឹង :
    - សួរឈ្មោះអ្នក
    - រកមើលនៅក្នុងបញ្ជីចុះឈ្មោះបោះឆ្នោត
    - សុំឲ្យអ្នកចុះហត្ថលេខា នៅក្នុងបញ្ជីឈ្មោះ
    - ឲ្យសន្លឹកបោះឆ្នោតទៅអ្នក។ (សូមចាំថា អ្នកអាចយកមនុស្សម្នាក់ទៅជាមួយបាន ឬក៏យកក្រដាសកត់ត្រាចំណាំថាអ្នកចង់បោះឆ្នោតយ៉ាងណានោះ ជាប់ជាមួយអ្នកបាន។ )
2. កន្លែងអ្នកត្រូវចុចក្រដាសសន្លឹកឆ្នោត។
    - អ្នកត្រូវចូលទៅក្នុងបន្ទប់ស្ងាត់មួយ
    - អ្នកត្រូវ ចុចសន្លឹកឆ្នោត នៅកន្លែងណាដែលអ្នកចង់ជ្រើសរើសយក។
3. អ្នកត្រូវដាក់សន្លឹកឆ្នោតទៅវិញ នៅក្នុងប្រអប់បិតជិត កាលណាអ្នកបានបោះឆ្នោតជ្រើសរើសចប់។

## តើខ្ញុំអាចបោះឆ្នោតបានឬទេ? បើខ្ញុំមិនយល់ច្បាស់អំពីចំណុចរឿងទាំងអស់ នៅលើក្រដាសបោះឆ្នោតនោះ

**អាចបាន.** អ្នកអាចបោះឆ្នោត យ៉ាងតិចឬច្រើនចំនួននៃចំណុចរឿង ទាំងឡាយនោះយ៉ាងណាក៏បាន តាមការយល់របស់អ្នក។ ការសំខាន់បំផុត គឺត្រូវតែយល់ឲ្យច្បាស់ នូវចំណុចមួយណា ដែលអ្នកប្រាថ្នាចង់បោះនោះ។

## តើធ្វើយ៉ាងម៉េចទៅ បើខ្ញុំធ្វើច្រឡំក្នុងការចុចសន្លឹកឆ្នោត នៅថ្ងៃដែលខ្ញុំបោះឆ្នោតនោះ។

បើសិនជាអ្នកធ្វើសន្លឹកឆ្នោតខុសនោះ គ្រាន់តែប្រាប់ទៅអ្នកធ្វើការនៅកន្លែងបោះឆ្នោតនោះ ហើយគេនឹងឲ្យអ្នក នូវសន្លឹកឆ្នោតថ្មីមួយទៀត។

## តើធ្វើយ៉ាងម៉េច បើខ្ញុំដឹងថា ខ្ញុំដូចជាគេធ្វើឲ្យភ័យខ្លាច នៅថ្ងៃបោះឆ្នោត នាកន្លែងជ្រើសរើសនោះ។

ការបោះឆ្នោត គឺជាសិទ្ធិរបស់ប្រជាពលរដ្ឋម្នាក់ៗ ដែលមានច្បាប់បោះឆ្នោត ត្រូវធ្វើការបោះនៅក្នុងបរិយាកាសឯករាជ្យ គ្មានការគំរាមកំហែង ឬការប្រកាន់ជាតិសាសន៍អ្វីឡើយ។ បើសិនជាអ្នកដឹងថាមានការបំភ័យពេលកំពង់បោះឆ្នោតនោះ អ្នកអាចទាក់ទងនឹង Office of the Registrar of Voters ឬ the Office of the Secretary of State។ បើសិនជាអ្នកដឹងខ្លួនថា អ្នកត្រូវរងគ្រោះដោយសារ ការស្អប់ ឬការពំពានធ្វើបាបអ្វីមួយ សូមទាក់ទងនៅកន្លែងធ្វើការ ២៤ម៉ោង Anti-Hate Hotline មានលេខ (408) 279-0111. ឬក៏ the Immigrant Q & A Information Line. (មើលនៅទំព័រខាងក្រោម ដើម្បីដឹងពីលេខទូរស័ព្ទផ្សេងទៀត។)

---

ការពិសោធន៍នៃការបោះឆ្នោតរបស់អ្នក គឺជាការ

**រីករាយសប្បាយ!!!**

ឲ្យដំណឹងភ្លាមពីការបំភ័យ និងកំឡាចណាមួយ

នៅថ្ងៃបោះឆ្នោត!!

---

### ចំណុចដែលត្រូវចាំ នៅពេលកំពុងបោះឆ្នោត :

- អ្នកអាច រកគេឲ្យជួយ។
- អ្នកអាច យកមិត្តភក្តិទៅជាមួយ។
- អ្នកអាច យកក្រដាសកត់ចំណាំ ទៅជាមួយ។
- អ្នកមិនចាំបាច់ ចុចឆ្នោតជ្រើសរើស គ្រប់អ្វីៗទាំងអស់ នោះទេ ដើម្បីមានន័យថាអ្នកបានបោះឆ្នោតនោះ។
- បើអ្នកមានការច្រឡំ អ្នកអាចសួររកសុំយកសន្លឹកឆ្នោតថ្មី មួយទៀត។

### League of Women Voters

Tel: 1 (800) 870-VOTE

### The Office of the Registrar of Voters

1555 Berger Dr., Bldg. #2, San José 95112
Tel: (408) 299-VOTE (8683)
Poll Workers: (408) 299-8344

អេស្ប៉ាញ៉ុល: **(408) 299-8344**
វៀតណាម: **(408) 299-8345**
ចិន: **(408) 299-8660**

**ម៉ោងធ្វើការ:** ចន្ទ-សុក្រ ម៉ោង ៨ព្រឹក-៥ល្ងាច

### Project Vote Smart

Tel: 1 (888) VOTESMART (1 (888) 868-3762)

ដើម្បីបានពត៌មានតាមទូរស័ព្ទ ជាភាសា អេស្ប៉ាញ៉ុល និងអង់គ្លេស
Tel: 1 (888) 622-SMART
Website: www.vote-smart.org

**Voter Assistance Hotline- Office of the Secretary of State**

Tel: 1 (800) 345-VOTE

**Services, Immigrant Rights & Education Network**

778 N. 1st. St. Ste. 200, San José 95112
Tel: (408) 286-5680
Immigrant Q& A Information Line: (see below)



ត្រូវការពត៌មានថែមទៀត? សូមទាក់ទងតាមខ្សែទូរស័ព្ទ SIREN's Immigrant Assistance & Information Line សំរាប់កម្មវិធីប្តូរថ្មី នឹងសំនួរជាទូទៅ។ ទូរស័ព្ទទាំងអស់មានបើក ពីថ្ងៃ ចន្ទ-សុក្រ ម៉ោង ១០ព្រឹក-៤ល្ងាច ហើយជាពីរភាសា អង់គ្លេសនឹងភាសាដូចតទៅ :
អេស្ប៉ាញ៉ូល- (408) 286-1698 វៀតណាម- (408) 286-1448 **Farsi**- (408) 286-5680 x108 នឹងចិន- (408) 286-5680 x109